**សេចក្តីប្រកាសព័ត៌មាន**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៩**

# ប្រព័ន្ធធារាសាស្ត្រ ៤ខ្សែ ត្រូវបានប្រគល់ជូនសហគមន៍ក្នុងខេត្តព្រៃវែង

ប្រព័ន្ធធារាសាស្ត្របួនខ្សែ ក្រោមជំនួយរដ្ឋាភិបាលអូស្ត្រាលី ត្រូវបានប្រគល់ជូនជាផ្លូវការដល់សហគមន៍នានាក្នុងខេត្តព្រៃវែង។

ប្រព័ន្ធធារាសាស្ត្រទាំងបួនខ្សែ នឹងផ្តល់ទឹកស្រោចស្រពពេញមួយឆ្នាំ ដល់កសិករជាង១៥០០ គ្រួសារ ក្នុងស្រុកព្រះស្តេច ពាមជរ ពាមរក៍ និងកំពង់ត្របែក ដែលអាចជួយកសិករឲ្យធ្វើស្រែបានពីរទៅបីដងក្នុងមួយឆ្នាំ។

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោកជំទាវ Angela Corcoran ថ្លែងថា៖ «នេះគឺជាឧទាហរណ៍មួយទៀត ដែលបង្ហាញថាកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍របស់រដ្ឋាភិបាលអូស្ត្រាលីនៅកម្ពុជា ផ្តល់នូវលទ្ធផលប្រកបដោយគុណភាពខ្ពស់ និងនិរន្តរភាពសម្រាប់កសិករកម្ពុជា»។

ឯកអគ្គរាជទូតអូស្ត្រាលី លោកជំទាវ Angela Corcoran បន្ថែមថា៖ «ខ្ញុំមានមោទនភាពចំពោះការងាររបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងការជួយដល់គ្រួសារ និងសហគមន៍នៅតាមតំបន់ជនបទក្នុងប្រទេសកម្ពុជា ដើម្បីបង្កើនប្រាក់ចំណូល និងត្រៀមខ្លួនសម្រាប់បញ្ហាប្រឈមរយៈពេលវែង ដូចជាកង្វះកម្លាំងពលកម្ម និងការប្រែប្រួលអាកាសធាតុជាដើម»។

ក្រោមជំនួយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីខ្សែសង្វាក់តំលៃកសិកម្មកម្ពុជា ហៅកាត់ថាកាវ៉ាក់ (CAVAC) ប្រព័ន្ធធារាសាស្ត្រទាំងបួនខ្សែនេះ មានតម្លៃប្រមាណជាប្រាំពីរលានដុល្លារសហរដ្ឋអាមេរិក។

ដោយប្រើប្រាស់ប្រឡាយបេតុង ប្រព័ន្ធធារាសាស្ត្រនីមួយៗ មានស្ថានីយ៍បូមទឹករួម និងបង្ហូរទឹកដោយផ្ទាល់នេះ គឺជាគំរូល្អជាងគេមួយ ក្នុងចំណោមប្រព័ន្ធធារាសាស្ត្រពេញលេញ ប្រកបដោយនិរន្តភាព (មានប្រឡាយមេ និងប្រឡាយរងជាច្រើនដែលអាចបង្ហូរទឹកដល់ស្រែដោយផ្ទាល់)។ ដោយផ្តោតសំខាន់លើការប្រើប្រាស់ទឹកប្រកបដោយនិរន្តភាព និងការចូលរួមយ៉ាងសកម្មពីសហាគមន៍ និងអាជ្ញាធរមូលដ្ឋាន ក្នុងការសាងសង់ និងការគ្រប់គ្រងប្រព័ន្ធទាំងនេះ នឹងជួយបង្កើនប្រាក់ចំណូលពីការដាំដុះ ប្រកបដោយស្ថេរភាពក្នុងរយៈពេលយូរអង្វែង។

ក្រោមការគាំទ្រពីមន្ទីរធានធានទឹកនិងឧតុនិយម កាវ៉ាក់ បានបង្កើត និងបណ្តុះបណ្តាលសហាគមន៍កសិករប្រើប្រាស់ទឹក ដើម្បីប្រតិបត្តិ និងថែទាំប្រព័ន្ធធារាសាស្ត្រ។ ការវិនិយោគបន្ថែមលើជំនាញ និងសមត្ថភាពរបស់កសិករ ក្នុងការប្រើប្រាស់ និងថែទាំប្រព័ន្ធទាំងនេះ ពិតជាមានភាពចាំបាច់ដើម្បីធានានូវភាពជាម្ចាស់ និងនិរន្តរភាព។

កាវ៉ាក់ មានគោលបំណងបង្កើនផលិតភាព និងប្រាក់ចំណូលដល់កសិករខ្នាតតូច ព្រមទាំងពាណិជ្ជកម្ម វិស័យស្រូវអង្ករ និងដំណាំផ្សេងៗ តាមរយៈការពង្រឹងប្រព័ន្ធទីផ្សារ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។ ចាប់តាំងពីឆ្នាំ២០១០ កាវ៉ាក់បានសាងសង់ និងកែរលម្អរឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ ៣០កន្លែង នៅក្នុងខេត្តកំពង់ធំ កំពត តាកែវ ព្រៃវែង និងកណ្តាល។ កាវ៉ាក់ គឺជាកម្មវិធីជំនួយធំជាងគេបំផុតរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងប្រទេសកម្ពុជា ដោយមានថវិកាសរុប ១៣០លានដុល្លារអូស្ត្រាលី (ឬស្មើនឹង៩២លានដុល្លារសហរដ្ឋអាមេរិក) ចាប់ពីឆ្នាំ២០១០ ដល់២០២១។

ព័ត៌មានបន្ថែមអំពីជំនួយអភិវឌ្ឍន៍អូស្ត្រាលីនៅកម្ពុជា សូមចូលទៅកាន់៖
https://dfat.gov.au/geo/cambodia/development-assistance/Pages/development-assistance-in-cambodia.aspx

ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ Australian.Embassy.Cambodia@dfat.gov.au